00286984

E2/92/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / MAR / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Huy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខៈ ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ

**Case File/Dossier No. 001/18-07-2007-ECCC/TC**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Huy

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចលើសំណើសុំពន្យារពេល
# ក្នុងការដាក់ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីជនជាប់ចោទ**
ការ សាវុត
François ROUX

យើងចៅក្រម **និល ណុន** ជាប្រធានអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-អវតក/អជសង តាម "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ ("សេចក្តីសម្រេច")។

**ក្រោយពីបានទទួល** "សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដែលបានស្នើសុំប្រធានអង្គជំនុំជម្រះសាលាដំបូង បន្តថេរវេលានៃរយៈពេលកំណត់សម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ដែលបានដាក់ជាសាធារណៈ ជាភាសាខ្មែរ និងជាភាសាអង់គ្លេសនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម១) ("ពាក្យសុំ")[1] ព្រមទាំងបានទទួលផងដែរនូវ "សេចក្តីកែតម្រូវ" លើពាក្យសុំនេះ ដែលបានដាក់នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩[2] ។

**ក្រោយពីបានពិចារណាលើ** សេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ភាគីក្នុងអំឡុងពេលសវនាការបឋមនៅថ្ងៃទី ១៧ និង១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ។

**អនុលោមតាម** វិធាន២៣(៤) នៃវិធានផ្ទៃក្នុង ។

## អង្គហេតុ និង សំអាងហេតុ

### ក. អំពីអង្គហេតុ

១. នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ តាងនាមឲ្យលោក **នង ចាន់ផល** មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម១) បានដាក់ពាក្យសុំមកប្រធានអង្គជំនុំជម្រះសាលាដំបូង ស្នើសុំបន្តថេរវេលានៃរយៈពេលកំណត់សម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ សំណើនេះត្រូវបានលើកឡើងសារជាថ្មីដោយផ្ទាល់មាត់នៅក្នុងអំឡុងពេលសវនាការបឋម។

២. លោក **នង ចាន់ផល** ដែលអះអាងថា គាត់ជាក្មេងដែលរស់រានមានជីវិតពីមន្ទីរឃុំឃាំង ស-២១ និងជាជនរងគ្រោះម្នាក់នៅក្នុងសំណុំរឿងលេខ០០១ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៩។ ពាក្យសុំនេះ ត្រូវបានអង្គភាពជនរងគ្រោះបដិសេធ ដោយផ្អែកលើមូលហេតុថា ពាក្យសុំតាំងខ្លួន

[1] ពាក្យបណ្តឹងស្នើសុំ ត្រូវបានដាក់នៅក្នុងលេខឯកសារ E2/92។

[2] ឯកសារលេខ E2/92/1

ជាដើមបណ្តឹងរដ្ឋប្បវេណីនេះ បានដាក់ក្រោយរយៈពេលកំណត់ចំនួនពីរថ្ងៃ គឺនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលកាលបរិច្ឆេទនេះត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន២៣(៤) នៃវិធានផ្ទៃក្នុង[3]។

៣. យោងតាមការលើកឡើងពីមេធាវីរបស់គាត់ ការទទួលស្គាល់លោក **នង ចាន់ផល** ជាដើមបណ្តឹងរដ្ឋប្បវេណីនឹងចូលរួមយ៉ាងសំខាន់ដល់ការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចដែលមានចែងនៅក្នុងច្បាប់របស់អ.វ.ត.ក និងវិធានផ្ទៃក្នុង ។ លោក **ចាន់ផល** មិនបានដឹងអំពីរយៈពេលកំណត់នៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្ទាប់ពីលោកត្រូវបានគេជូនដំណឹងអំពីរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លោកក៏បានទាក់ទងជាមួយអង្គភាពជនរងគ្រោះភ្លាម។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០១ របស់គាត់ ត្រូវបានដាក់ពីរថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការដាក់សុំបានកន្លងផុត ។ បន្ថែមលើនេះ វិធាន២៣(៤) បានចែងថា ប្រធានអង្គជំនុំជម្រះអាចពន្យារ ឬកាត់បន្ថយនូវរយៈពេលកំណត់ខាងលើនេះ ដោយសេចក្តីសម្រេចពិសេស។ មេធាវីរបស់គាត់ បានស្នើសុំមកប្រធានអង្គជំនុំជម្រះសាលាដំបូង ឲ្យអនុវត្តឆន្ទានុសិទ្ធិនិងសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើពាក្យសុំរបស់លោក **ចាន់ផល** ដូចដែលបានភ្ជាប់មកជាមួយនិងពាក្យសុំនេះ។

៤. នៅក្នុងអំឡុងពេលសវនាការបឋម ភាគីផ្សេងៗទៀតត្រូវបានអញ្ជើញឲ្យធ្វើសេចក្តីសន្និដ្ឋានតបទៅនិងការស្នើសុំនេះ ។ ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម៣) មេធាវីតំណាងរបស់គាត់បានសង្កេតឃើញថា គោលបំណងនៃវិធានផ្ទៃក្នុង គឺជាការរួមបញ្ចូលនូវច្បាប់នីតិវិធីជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ។ មេធាវីបានកត់សម្គាល់ថា តាមច្បាប់កម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យសុំចូលរួមដំណើរការនីតិវិធីនៅគ្រប់ដំណាក់កាលទាំងអស់ រហូតដល់សហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានសុំលើអង្គសេចក្តី ។

៥. សហព្រះរាជអាជ្ញាបានយល់ស្របថា ព័ត៌មានដែលផ្តល់ដោយអ្នកដាក់ពាក្យសុំ នឹងជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត ។ តាមការពិនិត្យលើអត្តចរិតពិសេសរបស់អ្នកដាក់ពាក្យសុំ សហព្រះរាជអាជ្ញាបានគាំទ្រលើការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលដាក់ហួសរយៈពេលកំណត់នេះ ។ នៅក្នុងជម្រើសមួយទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា អ្នកដាក់ពាក្យសុំ គួរត្រូវបានកោះហៅក្នុងឋានៈជាសាក្សីនៅពេល

[3] សូមមើលដីកាសម្រេចកំណត់កាលបរិច្ឆេទសវនាការបឋម ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩, ឯកសារលេខ E8



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C C B E T C

00286987



ជំនុំជម្រះ ដោយសារតែសក្ខីកម្មរបស់គាត់អាចពាក់ព័ន្ធចំពោះរឿងក្តី ។ ភស្តុតាងរបស់គាត់នឹងមិនធ្វើឱ្យខូចប្រយោជន៍ដល់មេធាវីការពារក្តីនោះទេ។

៦. មេធាវីការពារក្តីបានជំទាស់ទៅនឹងការស្តាប់ចម្លើយលោក **នង ចាន់ផល** ក្នុងឋានៈជាសាក្សី និងជំទាស់ទៅនិងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ។ មេធាវីការពារក្តីបានលើកឡើងថា ការទទួលយកកសិណសាក្សី និងភស្តុតាងថ្មីនៅនាទីចុងក្រោយ ត្រូវតែកំណត់ឱ្យបានតឹងរឹងដើម្បីការពាររដ្ឋបាលយុត្តិធម៌ឱ្យមានប្រសិទ្ធភាព និងការពារសិទ្ធិរបស់ជនជាប់ចោទ ។ ការបន្តថេរវេលានៃរយៈពេលកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ អាចនឹងបង្កើតជាយុត្តិសាស្ត្រសម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានហួសរយៈពេលកំណត់ផ្សេងៗទៀត ដែលជាផលវិបាកនាំឱ្យខូចប្រយោជន៍ដល់ជនជាប់ចោទចំពោះការជំនុំជម្រះឱ្យបានឆាប់រហ័ស ។

## ខ. អំពីសំអាងហេតុ

៧. អង្គជំនុំជម្រះកត់សម្គាល់ថា មាត្រា៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាជនរងគ្រោះអាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅគ្រប់ដំណាក់កាល នៅមុនពេលសេចក្តីសន្និដ្ឋានសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្តី ។ ដោយផ្អែកតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌខាងលើ វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង ចែងថា “ដើម្បីអាចទទួលយកបាន ជនរងគ្រោះត្រូវដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គភាពជនរងគ្រោះយ៉ាងតិចរយៈពេល១០ (ដប់) ថ្ងៃ នៃថ្ងៃការងារមុនកាលបរិច្ឆេទនៃសវនាការបឋម”។ ចំណុចនេះបង្ហាញពីសមត្ថកិច្ចដ៏ទូលំទូលាយរបស់ អ.វ.ត.ក ក្នុងការអនុម័តវិធានបន្ថែម “ក្នុងករណីដែលមានភាពចាំបាច់ក្នុងការរួមបញ្ចូលនូវក្រមនីតិវិធីជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីយកមកប្រើនៅចំពោះមុខតុលាការ” ឬ “ក្នុងករណីដែលក្រមនីតិវិធីជាធរមានមិនអាចដោះស្រាយនូវបញ្ហាពិសេសណាមួយ ឬក្នុងករណីដែលការបកស្រាយឬការអនុវត្តន៏មិនមានភាពច្បាស់លាស់ ឬ ក្នុងករណីមានបញ្ហាចោទទាក់ទងនឹងភាពស៊ីសង្វាក់គ្នាជាមួយនិងបទដ្ឋានអន្តរជាតិ”[4] ។

៨. អង្គជំនុំជម្រះកត់សម្គាល់ថា វិសាលភាពនៃបទល្មើសនានានៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក និងចំនួនជនរងគ្រោះជាច្រើនសន្ធឹកសន្ធាប់បែបនេះ គឺមិនធ្លាប់មានពីមុនទេនៅចំពោះមុខតុលាការកម្ពុជា ។ វិធាន២៣(៤) ចែងបំពេញបន្ថែមលើក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីជួយសម្រួល

---

[4] កថាខណ្ឌប្រាំនៃបុព្វកថា វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (កំណែលើកទី២) ថ្ងៃទី [illegible] ឆ្នាំ២០០៨។ សេចក្តីសម្រេចលើពាក្យសុំពន្យាពេលក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី/សាធារណៈ/ ១០ មីនា ២០០៩

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C • E T C

ដល់ការគ្រប់គ្រងសំណុំរឿងដ៏ស្មុគស្មាញ ដែលមានជនរងគ្រោះដ៏ច្រើននាក់ ។ រយៈពេលកំណត់ដែលចែងនៅក្នុងវិធានមួយនេះ បានបង្ហាញអំពីចរិតលក្ខណៈ*ពិសេស*របស់ អ.វ.ត.ក និងភាពចាំបាច់ដើម្បីធានានូវការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស ទាក់ទងនឹងសំណុំរឿងមានទ្រង់ទ្រាយធំៗ និងស្មុគស្មាញ ដែលជាទូទៅតុលាការជាតិមិនធ្លាប់មានពីមុនមក ។ ការរៀបចំប្រកបដោយប្រសិទ្ធភាពនៃការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក គឺកាន់តែចាំបាច់ ដើម្បីអាចឱ្យភាគីនានាអនុវត្តនូវសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពតាមវិធានផ្ទៃក្នុង ដូចជាការដាក់សាក្សីបន្ថែម ដោយអនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង។

៩. អនុលោមតាមវិធាន២៣(៤) ទោះបីជាប្រធានអង្គជំនុំជម្រះ អាចកែប្រែរយៈពេលកំណត់សម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ការអនុវត្តឆន្ទានុសិទ្ធិនេះត្រូវតែមានមូលហេតុច្បាស់លាស់។ លើសពីនេះ អង្គជំនុំជម្រះត្រូវធានានូវការប្រព្រឹត្តដូចៗគ្នាចំពោះជនរងគ្រោះទាំងអស់ និងជៀសវាងនូវការស្តែងឱ្យឃើញ នូវករណីលើកលែងចំពោះបុគ្គលណាមួយនោះឡើយ ។ អាស្រ័យហេតុនេះ ការពន្យារពេលសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាមួយ អាចនាំឱ្យមានការពន្យារពេលនៃរយៈពេលកំណត់ចំពោះអ្នកដាក់ពាក្យសុំទាំងអស់ ឬអាចនិងផ្តល់ការបន្តពេលត្រឹមតែនៅក្នុងកាលៈទេសៈពិសេស នៅក្នុងករណីដែលមានការស្នើសុំទាក់ទងនឹងអ្នកដាក់ពាក្យសុំពិសេសណាមួយ ។ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីដែលតំណាងឱ្យលោក **ចាន់ផល** មិនបានផ្តល់ព័ត៌មានណាមួយដល់អង្គជំនុំជម្រះ ដែលបង្ហាញថាកាលៈទេសៈពិសេសបានរារាំងគាត់មិនឱ្យដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរយៈពេលកំណត់ដែលបានចែងនោះទេ ។ អង្គជំនុំជម្រះបានកត់សម្គាល់បន្ថែមថា អ.វ.ត.ក បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជូនដំណឹងដល់សាធារណៈជន អំពីរយៈពេលកំណត់ចំពោះការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងសនិទានភាពក្នុងការកំណត់រយៈពេលទាំងនោះ[5] ។ ដោយហេតុផលទាំងអស់នេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធពាក្យស្នើសុំនេះ។ អង្គជំនុំជម្រះសូមរក្សាសិទ្ធិក្នុងការសម្រេចថាតើត្រូវកោះហៅ ឬមិនកោះហៅលោក **នង ចាន់ផល** មកធ្វើជាសាក្សីនៅពេលក្រោយ។

## សេចក្តីសម្រេច

[5] សូមមើលសេចក្តីប្រកាសព័ត៌មានរបស់អ.វ.ត.ក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨។ សូមមើលដីកាសម្រេចកំណត់កាលបរិច្ឆេទនៃសវនាការបឋមរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ (ឯកសារលេខ E8)។ សូមមើលសេចក្តីប្រកាសព័ត៌មានរបស់អង្គភាពជនរងគ្រោះ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩ ។ សូមមើលសេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

**ផ្អែកតាមសំអាងហេតុខាងលើ**

**សម្រេចបដិសេធ** លើពាក្យសុំនេះ ។

ភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩
**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C • C E T C

និល នន្ទ